**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែតុលា ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែតុលានេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ២ ៧៦៤ ០៤០ហ.ត ស្មើនឹង១០៥,៥២% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត។ វិធានការជួយសង្គ្រោះបន្ទាន់ និងវិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេស បទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែតុលា ឆ្នាំ២០២២នេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់ ការប្រជុំពិចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២២ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងខែតុលា ឆ្នាំ២០២២ នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១- លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សាបញ្ចប់

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៧៦៨ ៥៩៧ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៩ ៣៨១ហ.ត ស្មើនឹង០,៣៤% និងដោយគ្រឿងយន្តចំនួន ២ ៧៥៩ ២១៦ហ.ត ស្មើនឹង៩៩,៦៦% តិចជាងឆ្នាំមុន ១៥៧ ២៣១ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ១០ ១៤១ហ.ត តិចជាងឆ្នាំមុន ២ ២៥១ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៧៦៤ ០៤០ហ.ត ស្មើនឹង១០៥,៥២% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត តិចជាងឆ្នាំមុន ១៣៧ ៥៦៥ហ.ត។

#### ១.២ ការប្រមូលផលស្រូវស្រាលរដូវវស្សា

ការប្រមូលផលស្រូវស្រាលសម្រេចចំនួន ៥៦៧ ៩៩៩ហ.ត ទទួលបរិមាណផលសរុបចំនួន ២ ២៥០ ១៣៨តោន និងទទួលបានទិន្នផលគិតជាមធ្យម ៣,៩៦២តោន/ហ.ត។

#### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៥២ ៤១២ហ.ត ស្មើនឹង៩០,៥២% នៃផែនការចំនួន ៥៧ ៩០០ហ.ត តិចជាងឆ្នាំមុន ៧ ៧២៨ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៨៦៥ ០៨២ហ.ត ស្មើនឹង១១១,១៥% នៃផែនការចំនួន ៧៧៨ ៣០០ហ.ត លើសឆ្នាំមុន ៤៩ ៣០៤ហ.ត។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

### ១.៤ ស្ថានភាពប៉ះពាល់ ខូចខាត និងការស្តារឡើងវិញ

ផ្ទៃដីរងផលប៉ះពាល់ដោយសារជំនន់ទឹកភ្លៀងនៅតាមបណ្តារាជធានី-ខេត្តចំនួន២២ មានចំនួន ២៨៨ ៤៥៧ហ.ត ស្មើនឹង៧,៨៤% នៃផ្ទៃដីអនុវត្តសរុប។ ផ្ទៃដីខូចខាតសរុបចំនួន ១៥៣ ៤៣៨ហ.ត ស្មើនឹង៥៣,១៩% និងផ្ទៃដីស្តារឡើងវិញបានសរុបចំនួន ៨០ ៩៦៣ហ.ត ស្មើនឹង៤៧,៥៥% នៃផ្ទៃដីខូចខាតសរុប។

### ១.៥ ការនាំចេញផលិតផលកសិកម្ម

#### ១.៥.១ ការនាំចេញអង្ករ

បរិមាណការនាំចេញអង្កររយៈពេល១០ខែមានចំនួន ៥០៩ ២៤៩តោន កើនឡើងចំនួន ៤៩ ០៨០តោន (១០,៦៧%) បើធៀបនឹងបរិមាណនាំចេញរយៈពេល១០ខែ ឆ្នាំ២០២១ មានចំនួន ៤៦០ ១៦៩តោន។ ដោយឡែកខែតុលា ឆ្នាំ២០២២ មានចំនួន ៥៩ ៨៨៨តោន កើនឡើងចំនួន ១០ ៤១៧តោន (២១,០៦%) បើធៀបនឹងខែតុលា ឆ្នាំ២០២១ មានចំនួន ៤៩ ៤៧១តោន។

អង្ករក្រអូបគ្រប់ប្រភេទមានចំនួន ៣៤៨ ៥០១តោន ស្មើនឹង ៦៨,៤៤% អង្ករសគ្រប់ប្រភេទមានចំនួន ១៤៨ ៩៣៣តោន ស្មើនឹង ២៩,២៤% និងអង្ករចំហុយគ្រប់ប្រភេទមានចំនួន ១១ ៨១៥តោន ស្មើនឹង ២,៣២%។

បរិមាណអង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២៣ប្រទេស មានបរិមាណសរុបចំនួន ១៦៥ ៦៣០តោន (កើនឡើងចំនួន ៥០ ១៥៤តោន ស្មើនឹង ៤៣,៤៣%) ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ២៣១ ៨៧៣តោន (កើនឡើងចំនួន ២ ៦៩៦តោន ស្មើនឹង ១,១៨%) ទិសដៅអាស៊ានចំនួន ៤ប្រទេស មានបរិមាណសរុបចំនួន ៤៨ ២៥៣តោន (កើនឡើងចំនួន ៤ ៤៦៣តោន ស្មើនឹង ១០,១៩%) និងទិសដៅដទៃទៀតចំនួន ២៦ប្រទេស មានបរិមាណសរុប ៦៣ ៤៩៣តោន (ថយចុះចំនួន ៨ ២៣៣តោន ស្មើនឹង -១១,៤៨%)។

ក្រុមហ៊ុនដែលបាននាំចេញអង្ករមានចំនួន ៥៥ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន១០ មានរហូតដល់ ៣៤៣ ៩៤៩តោន (៦៧,៥៤%) និងក្រុមហ៊ុន៤៥ ដទៃទៀតបាននាំចេញត្រឹមតែ ១៦៥ ៣០០តោន (៣២,៤៦%)។

#### ១.៥.២ ការនាំចេញស្រូវ

ក្នុងរយៈពេល១០ខែឆ្នាំ២០២២ ការនាំចេញស្រូវមានចំនួន ២ ៤៤០ ១១២តោន ទៅកាន់ប្រទេសវៀតណាម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ១ ៦៤៣ ៥៥០តោន) ថយចុះចំនួន ២១៩ ៨៧៨តោន (-៨,២៧%) បើធៀបនឹងរយៈពេល១០ខែឆ្នាំ២០២១ ដែលមានចំនួន ២ ៦៥៩ ៩៩០តោន។

#### ១.៥.៣ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ

ក្នុងរយៈពេល១០ខែឆ្នាំ២០២២ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ៤ ៦៦៩ ៩៧៤,២៥តោន កើនឡើងចំនួន ៤៤៨ ៨២១,០៣តោន ស្មើនឹង១០,៦៣% បើធៀបនឹងរយៈពេល១០ខែឆ្នាំ២០២១ ដែលមានចំនួន ៤ ២២១ ១៥៣,២២តោន ដែលក្នុងនោះរួមមាន៖

- ចំណិតដំឡូងមីក្រៀមមានចំនួន ១ ៦៧០ ០៩០តោន (កើនឡើងចំនួន ២៤,៩៨%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ១ ១៩៣ ៣០០តោន និងប្រទេសវៀតណាមចំនួន ៤៧៦ ៧៩០តោន
- ដំឡូងមីស្រស់មានចំនួន ១ ១២៩ ០០០តោន (កើនឡើងចំនួន ៥១,៨០%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៦៧៤ ៨០០តោន និងប្រទេសថៃចំនួន ៤៥៤ ២០០តោន
- ម្សៅដំឡូងមីមានចំនួន ៥២ ០៩៣តោន (កើនឡើងចំនួន ៩៣,១៤%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៥០ ២២៥តោន សហរដ្ឋអាមេរិកចំនួន ៦៦៦តោន ប្រទេសអ៊ីតាលីចំនួន ៥៦៥តោន ប្រទេសវៀតណាមចំនួន ២១០តោន ប្រទេសណេដឺឡែនចំនួន ១៥២តោន ប្រទេសកាណាដាចំនួន ១០២តោន ប្រទេសថៃចំនួន ៩៨,៦០តោន ប្រទេសម៉ាឡេស៊ីចំនួន ៣៨,៤០តោន ប្រទេសសិង្ហបុរីចំនួន ១៩តោន និងប្រទេសឥណ្ឌាចំនួន ១៧តោន
- កាកសំណល់ដំឡូងមីមានចំនួន ៩ ១៧៩,៣៩តោន (កើនឡើងចំនួន ២៥,៨១%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៧ ៦២៤,៣៩តោន និងប្រទេសវៀតណាមចំនួន ១ ៥៥៥តោន
- គ្រាប់ស្វាយចន្ទីឆៅមានចំនួន ៤៦៩ ៥១៥,១៥តោន (ថយចុះចំនួន -៤៨,៥៩%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៤៦៧ ៣០១,២២តោន ប្រទេសថៃចំនួន ២ ០៥០តោន ប្រទេសឥណ្ឌាចំនួន ១៥០,១៦តោន ប្រទេសចិនចំនួន ១៣,៥៨តោន ប្រទេសជប៉ុនចំនួន ០,១៤តោន និងប្រទេសហ្វីលីពីនចំនួន ០,០៥តោន

- គ្រាប់ស្វាយចន្ទីកែច្នៃមានចំនួន ៥៩៩,៩៣តោន (ថយចុះចំនួន -៥៨,៩៣%) ក្នុងនោះនាំចេញទៅប្រទេសថៃ ចំនួន ២៦៤,៤៤តោន ប្រទេសចិនចំនួន ២២៩,៨៤តោន ប្រទេសជប៉ុនចំនួន ៧៤,៤៣តោន កោះតៃវ៉ាន់ចំនួន ២៤តោន ប្រទេសកូរ៉េចំនួន ៧,១០តោន និងប្រទេសស្វីសចំនួន ០,១២តោន

- គ្រាប់ពោតមានចំនួន ១៥៤ ៩៤៨,៩៤តោន (ថយចុះចំនួន -១,៣៩%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាម ចំនួន ១០៦ ០៤០តោន ប្រទេសថៃចំនួន ៤៨ ០០០តោន កោះតៃវ៉ាន់ចំនួន ៨៩៦,៦៤តោន និងប្រទេសកូរ៉េចំនួន ១២,៣០តោន

- គ្រាប់សណ្តែកបាយមានចំនួន ៣៥ ០២៥,០១តោន (កើនឡើងចំនួន ៣៨,១៥%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៣៥ ០២៥តោន និងប្រទេសជប៉ុនចំនួន ០,០១តោន

- គ្រាប់សណ្តែកសៀងមានចំនួន ១១៥ ៩៣៥តោន (កើនឡើងចំនួន ១២២,០៥%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៩៦ ៦៨៥តោន និងប្រទេសថៃចំនួន ១៩ ២៥០តោន

- ផ្លែចេកស្រស់មានចំនួន ៣២៥ ៨៥៩,៧២តោន (ថយចុះចំនួន -១១,៧៩%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ២៩៣ ០៦០,៣៩តោន ប្រទេសវៀតណាមចំនួន ៣២ ៧៩៩,២៣តោន និងប្រទេសជប៉ុនចំនួន ០,១០តោន

- ផ្លែស្វាយស្រស់មានចំនួន ១៣៨ ៣៧៧,៥៥តោន (ថយចុះចំនួន -៣១,៥៤%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៧៨ ៥៦៦,២៣តោន ប្រទេសថៃចំនួន ៣២ ១៨១,១២តោន ប្រទេសចិនចំនួន ២៧ ៤៦៧,៨៨តោន ប្រទេសកូរ៉េចំនួន ១៦០,០៨តោន និងទីក្រុងហុងកុងចំនួន ២,២៤តោន

- ដំណាប់ស្វាយមានចំនួន ១៥ ៨១៦,៦៩តោន (កើនឡើងចំនួន ១,០៦%) ក្នុងនោះនាំចេញទៅប្រទេសចិន ចំនួន ១៣ ៨៥១,៩៥តោន ប្រទេសថៃចំនួន ៩៦៨,២១តោន ប្រទេសហ្វីលីពីនចំនួន ៥៧១,៧៧តោន ប្រទេសវៀតណាមចំនួន ២០០តោន ប្រទេសជប៉ុនចំនួន ១១១,៥៤តោន ប្រទេសរុស្ស៊ីចំនួន ៧១,០៥តោន ប្រទេសអ៊ីតាលីចំនួន ២៦,៤៦តោន ចក្រភពអង់គ្លេសចំនួន ៩,៧៨តោន ប្រទេសកូរ៉េចំនួន ៥,៨៩តោន សហរដ្ឋអាមេរិកចំនួន ០,០៣តោន និងប្រទេសអូស្ត្រាលីចំនួន ០,០១តោន

- ដូងប្រេងមានចំនួន ៥៤ ៨៧៨,៧០តោន (កើនឡើងចំនួន ១២,៥១%) ក្នុងនោះនាំចេញទៅប្រទេសឥណ្ឌាចំនួន ៤៤ ៤០៦,៧០តោន ប្រទេសម៉ាឡេស៊ីចំនួន ៩ ៤៨០តោន ប្រទេសវៀតណាមចំនួន ៨០០តោន និងប្រទេសថៃចំនួន ១៩២តោន

- ម្រេចមានចំនួន ៧ ៧០៤,២៥តោន (ថយចុះចំនួន -៧២,១២%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាម ចំនួន ៦ ៦៤៥,៧៨តោន ប្រទេសអាល្លឺម៉ង់ចំនួន ៩២៨,២០តោន សហរដ្ឋអាមេរិកចំនួន ២៦,១០តោន កោះតៃវ៉ាន់ចំនួន ២១តោន ប្រទេសបារាំងចំនួន ១៩,៦៨តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ១៨,៦៧តោន ប្រទេសម៉ាឡេស៊ីចំនួន ១៤,២៤តោន សាធារណរដ្ឋឆេកចំនួន ១១,៣០តោន ប្រទេសកូរ៉េចំនួន ៧,២៦តោន ប្រទេសជប៉ុនចំនួន ៣,០៣តោន ប្រទេសស៊ុយអ៊ែតចំនួន ២,៧៨តោន ប្រទេសស្វីសចំនួន ២,១២តោន ប្រទេសកាណាដាចំនួន ១,២៨តោន ចក្រភពអង់គ្លេសចំនួន ១តោន ប្រទេសឥណ្ឌាចំនួន ០,៩២តោន ប្រទេសលីទុយអានីចំនួន ០,៤៥តោន ប្រទេសកាហ្សាក់ស្ថានចំនួន ០,៣០តោន ប្រទេសអូស្ត្រាលីចំនួន ០,១០តោន ប្រទេសរុស្ស៊ីចំនួន ០,០៣តោន និងប្រទេសណេដឺឡែនចំនួន ០,០១តោន

- ថ្នាំជក់មានចំនួន ៥ ៦៩៧,២៥៤តោន (កើនឡើងចំនួន ៤៤,៨២%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៥ ៥៩៤,៧០តោន កោះតៃវ៉ាន់ចំនួន ៤៧,២៥តោន ប្រទេសហុងគ្រីចំនួន ៣៩,៦០តោន ប្រទេសហ្វីលីពីនចំនួន ១៥,១១តោន ប្រទេសអេស្ប៉ាញចំនួន ០,៥៧តោន ប្រទេសអាហ្វ្រិកខាងត្បូងចំនួន ០,០២តោន និងប្រទេសប៊ុលហ្គារីចំនួន ០,០០៤តោន

- បន្លែចម្រុះមានចំនួន ៨០,៤៧តោន (ថយចុះចំនួន -៤,៦៦%) ក្នុងនោះនាំចេញទៅប្រទេសបារាំងចំនួន ៨០,៤៣តោន និងប្រទេសនូវែលសេឡង់ចំនួន ០,០៤តោន

- ផលិតផលចំនួន ៩៣មុខ ផ្សេងទៀតមានចំនួន ៤៨៥ ១៧៣,២០តោន។

**១.៥.៤ ការប៉ាន់ស្មានតម្លៃនៃការនាំចេញកសិផល**

ការប៉ាន់ស្មានតម្លៃគិតជាទឹកប្រាក់រយៈពេល១០ខែឆ្នាំ២០២២ ដែលទទួលបានពីការនាំចេញកសិផល (ឯកតាតម្លៃផ្អែកតាមវិក្កយបត្ររបស់អ្នកនាំចេញ) មានចំនួន ៣ ០៦៩ ៩៧២ ៣៤៩,០៨ដុល្លារអាមេរិក ដែលក្នុងនោះ៖

- ការនាំចេញអង្ករមានចំនួន ៤៣៥ ៤០៧ ៨៩៥ដុល្លារអាមេរិក
- ការនាំចេញស្រូវមានចំនួន ៤៩២ ៩០២ ៦២៤ដុល្លារអាមេរិក

- ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ២ ១៤១ ៦៦១ ៨៣០,០៨ដុល្លារអាមេរិក។

## ២- ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ០៤៤ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៧ ៩៤៤ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩២ ៤០២ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦៣ ៦៩៨ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ៣១០ ១៩៣ហ.ត ស្មើនឹង៧៧% និងផ្ទៃដីថែទាំចំនួន ៩៣ ៨៥១ហ.ត ស្មើនឹង២៣%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូក្នុងខែកញ្ញាសម្រេចបានចំនួន ៣៣ ៩១៣តោន បានកើនឡើងចំនួន ១ ៣៧៧តោន ស្មើនឹង៤% ធៀបនឹងខែមុន និងបានថយចុះចំនួន ៨៩៧តោន ស្មើនឹង៣% ធៀបនឹងខែកញ្ញា ឆ្នាំ២០២១

- ផលិតផលឈើកៅស៊ូក្នុងខែកញ្ញាសម្រេចបានចំនួន ៣ ៤៦៧ម$^{៣}$ បានកើនឡើងចំនួន ៣៤០ម$^{៣}$ ស្មើនឹង៩% ធៀបនឹងខែមុន។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូក្នុងខែកញ្ញាសម្រេចបានចំនួន ៣៣ ៥៨៦តោន បានកើនឡើងចំនួន ១ ១៣៥តោន ស្មើនឹង៣,៥% ធៀបនឹងខែមុន និងបានថយចុះចំនួន ៧២៦តោន ស្មើនឹង២% ធៀបនឹងខែកញ្ញា ឆ្នាំ២០២១

- បរិមាណបញ្ចេញលក់ឈើកៅស៊ូក្នុងខែកញ្ញាសម្រេចបានចំនួន ១ ២០៣ម$^{៣}$ បានថយចុះចំនួន ១ ៨៩៧ម$^{៣}$ ស្មើនឹង៦១% ធៀបនឹងខែមុន។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃលក់ជ័រកៅស៊ូគិតជាមធ្យមក្នុងខែកញ្ញា គឺ១ ៣១១ដុល្លារ/តោន បានថយចុះចំនួន ១២១ដុល្លារ/តោន ស្មើនឹង៨,៤៥% ធៀបនឹងខែមុន និងបានថយចុះចំនួន ៣១៨ដុល្លារ/តោន ស្មើនឹង២០% ធៀបនឹងខែកញ្ញា ឆ្នាំ២០២១

- តម្លៃលក់ឈើកៅស៊ូគិតជាមធ្យមក្នុងខែកញ្ញា គឺ១៨៧ដុល្លារ/ម$^{៣}$

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារខែកក្កដា គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៤ ៧៥០រ/គ.ក្រ ដល់ ៥ ៤០០រ/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ០២៥រ/គ.ក្រ ដល់ ៣ ១០០រ/គ.ក្រ។

## ៣- ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- ទាញយករូបភាពផ្កាយរណប (SENTINEL_2) ឆ្នាំ២០២២ បានចំនួន ១៦ផ្ទាំង និងបានចាត់ថ្នាក់បឋម សម្រាប់ចុះពិនិត្យជាក់ស្តែងនៅទីវាល

- ចុះកំណត់តំបន់សក្ខានុពលព្រៃសហគមន៍ចំនួន ១កន្លែង គឺតំបន់សក្ខានុពលព្រៃសហគមន៍ភ្នំព្រះធាតុ ក្នុងខេត្តកំពង់ឆ្នាំងមានផ្ទៃដីទំហំ៦០៣,៧៦ហ.ត

- ចុះប្រជុំពិនិត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងការអភិវឌ្ឍជីវភាពសហគមន៍ព្រៃឈើចំនួន ៤រួមមានៈ សហគមន៍ព្រៃឈើឆែបលិច សហគមន៍ព្រៃឈើក្រសាំង សហគមន៍ព្រៃឈើភ្នំដែកចំបក់ហោះ និងសហគមន៍ព្រៃឈើ សាមគ្គីត្រពាំងទទឹម ក្នុងខេត្តព្រះវិហារ មានអ្នកចូលរួមចំនួន ៨៨នាក់ (ស្រី៣៦នាក់)

- សហការជាមួយគម្រោងវ៉េដបូកទំរឹងរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍ត្រពាំងផ្អៅ និង សហគមន៍ព្រៃឈើកំពប់អំបិល ព្រមទាំងចុះសម្របសម្រួលការងារល្បាតសហគមន៍ព្រៃឈើចំនួន ១៤កន្លែងក្នុង ខេត្តកំពង់ធំ។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- ចុះធ្វើការសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យសត្វព្រៃនៅតំបន់សហគមន៍ព្រៃឈើប្រាសាទទឹកខ្មៅ ខេត្ត ក្រចេះ ដោយពិនិត្យមើលលើម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ៥គ្រឿងដែលបានដំឡើងរួចដើម្បីពិនិត្យ តាមដាន និង ផ្ទៀងផ្ទាត់វត្តមានចំនួន និងប្រភេទសត្វព្រៃដែលកំពុងរស់នៅ និងបន្តពូជនៅក្នុងតំបន់

- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃជូនក្រុមហ៊ុនចំនួន ២ច្បាប់មានស្វាក្តាមចំនួន ១ ៤៨៨ក្បាល។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្កាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៩ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្កាមយកកូននាំចេញចំនួន ៦ទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមាន ស្វាក្កាមចំនួន ១៣៩ ៦០៥ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៤ ៨៦៣ក្បាល
- កំពុងថែរក្សាសត្វព្រៃចំនួន ១ ៨៦២ក្បាល (បក្សី៥៩ប្រភេទ ថនិកសត្វ៤៥ប្រភេទ និងល្មូន១៦ប្រភេទ)
- សង្គ្រោះសត្វព្រៃថ្មីចំនួន ៧០ក្បាល ព្យាបាលចំនួន ២៤ក្បាល និងស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ
- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ២៦នាក់ បានចុះល្បាត នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺអារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)
- ជួសជុលផ្លូវដោយក្រាលក្រួសក្រហមសរុបប្រវែង៨គីឡូម៉ែត្រ និងអនាម័យព្រៃបាន៤.៣ហ.ត។

### ៣.៤ ការងារដាំដើមឈើ

- ចុះពិនិត្យទីតាំងសួនភូតគាមស្ថិតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដើម្បីត្រៀម សហការជាមួយរដ្ឋបាលខេត្តព្រះសីហនុ ក្នុងការបោះបង្គោលព្រំប្រទល់ និងសាងសង់ខ្លោងទ្វាសួនភូតគាម
- បាននិងកំពុងថែទាំចម្ការឈើសរុបទំហំ៧៤៧ហ.ត ក្នុងនោះចម្ការពូជឈើទំហំ៩៤ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ៣៩ហ.ត ចម្ការឈើដាំទំហំ៥៨៤ហ.ត និងចម្ការរុក្ខទិវា ៩កក្កដា សរុបទំហំ៣០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្តាល ព្រះសីហនុ កំពង់ធំ កំពង់ឆ្នាំង និងខេត្តក្រចេះ
- ដាំឈើជាចម្ការថ្មីទំហំ១៥ហ.ត នៅខេត្តកំពង់ធំ
- បណ្តុះកូនឈើបានចំនួន ៣៦ ៣១៨ដើម ដោយថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើ រាជធានី-ខេត្ត និងបានចែកចាយកូនឈើចំនួន ១៨៥ ៨៣១ដើម ក្នុងនោះថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌ រដ្ឋបាលព្រៃឈើរាជធានី-ខេត្តចំនួន ១៦០ ៥៣១ដើម និងថ្នាលបណ្តុះកូនឈើទាំង ៦មានចំនួន ២៥ ៣០០ដើម។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុម អន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន ៦៧ករណី ក្នុងនោះ សំណុំរឿងបទល្មើស ព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន ២៤ករណី និងសំណុំរឿងបទល្មើសព្រៃឈើដែលត្រូវបញ្ជូនទៅតុលាការចំនួន ៤៣ករណី
- វត្ថុតាងនៃបទល្មើសព្រៃឈើបានចាប់ឃាត់ និងដកហូតរួមមានឈើមូល-ជ្រុងចំនួន ១២ម$^{៣}$ ឈើអារចំនួន ៤៣ម$^{៣}$ សត្វព្រៃចម្រុះប្រភេទចំនួន ១០៦ក្បាល និង៩គ.ក្រ ផ្ទៃដីព្រៃឈើបានកាប់រានទំហំ២៩០ហ.ត អនុផលព្រៃឈើ និងឧបករណ៍សម្ភារផ្សេងៗមួយចំនួនទៀត
- វត្ថុតាងជាសត្វព្រៃ និងសំណាកសត្វព្រៃបានប្រមូលតាមរយៈការប្រគល់-ទទួលចំនួន ៤៤ករណី ធ្វើ កិច្ចសន្យាចំនួន ៧ករណី ធ្វើការដកហូតចំនួន ៦ករណី
- ធ្វើបច្ចុប្បន្នភាពសំណុំរឿងបទល្មើសព្រៃឈើ និងសត្វព្រៃតាមរយៈការបង់ប្រាក់ពិន័យដោយតុលាការ ចំនួន ១ករណី។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ចុះពិនិត្យសំណើសុំពន្យាររោងម៉ាស៊ីនអារកែច្នៃផល អនុផលព្រៃឈើចំនួន ១កន្លែងក្នុងខេត្តមណ្ឌលគិរី
- ក្រុមហ៊ុនចំនួន២នាំចេញផលិតផលរានទេវតាទៅក្រៅប្រទេសចំនួន ៦៣ម$^{៣}$ និងជ័រទឹកចំនួន ២៣តោន
- ក្រុមហ៊ុនចំនួន១នាំចូលឈើកែច្នៃចំនួន ៥៩ម$^{៣}$។

### ៣.៧ ការងារចំណូលព្រៃឈើ

- ចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួនសរុប ១៨១ ៧៩៨ ០២៤រៀល។

## ៤- ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ

### ៤.១ ការងារផលិតកម្មសត្វ

បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេស ចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ នៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដាន ស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្តៈ (ក) ការងារ

កែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្លនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

**៤.២ ការងារសុខភាពសត្វ**

**៤.២.១ លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ**

ចុះត្រួតពិនិត្យសុខភាពសត្វជាប្រចាំនៅទីទួលសុវត្ថិភាពសត្វដែលរងផលប៉ះពាល់ដោយទឹកជំនន់ទឹកភ្លៀង ក្នុងករណីសត្វឈឺត្រូវ ពិនិត្យ និងព្យាបាលជាបន្ទាន់ បំបែកសត្វឈឺចេញពីសត្វជា ចាក់ថ្នាំការពារ យកវត្ថុវិភាគមកមន្ទីរពិសោធន៍ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វក្នុងករណីចាំបាច់ ។ រាជធានី-ខេត្តចំនួន២៤ បាននិង កំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៧ ០៦៤លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។

**៤.២.២ ការងារផ្សព្វផ្សាយបច្ចេកទេស**

រៀបចំចងក្រងឯកសារបច្ចេកទេស និងសម្ភារសម្រាប់ការដាក់តាំងពិព័រណ៍អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅខេត្តកំពង់ចាម។

**៤.២.៣ ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេសនិងនីតិកម្មលើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ។

**៤.៣ ការងារស្រាវជ្រាវ**

**៤.៣.១ ការងារស្រាវជ្រាវផលិតកម្ម**

បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១២០ក្បាល។

**៤.៣.២ ការងារស្រាវជ្រាវសុខភាពសត្វ**

ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាន និងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបបានចំនួន ១ ៩៩៩វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) និងជំងឺដុំពកស្បែកគោ ក្របី (LSD)។ វត្ថុវិភាគចំនួន ៥៦មានប្រភពមកពីភូមិត្រពាំងរមាស ភូមិជួរថ្នល់ ភូមិកន្លែងជ្រៅ និងភូមិត្បូងវត្ត ឃុំជាច ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង និងភូមិរមាសហែក ភូមិព្រៃកឫស្សី ភូមិព្រៃក្តី និងភូមិត្រពាំងស្គន់ ស្រុករមាសហែក ខេត្តស្វាយរៀង រិជ្ជមានជំងឺដុំពកស្បែកគោក្របី (LSDV)។

## ៥- ផ្នែកជលផល

**៥.១ អាជីវកម្មនេសាទ**

**៥.១.១ នេសាទទឹកសាប**

- ដាយត្រីសម្រេចបានចំនួន ២០តោន សរុបរយៈពេល១០ខែចំនួន ៦៧០តោន ស្មើនឹង៦,៧០% នៃផែនការចំនួន ១០ ០០០តោន ប្រៀបធៀបខែតុលា ឆ្នាំ២០២១ ថយចុះចំនួន ៦៦០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ១៨ ៨០០តោន សរុបរយៈពេល១០ខែចំនួន ១៦៦ ៤០០តោន ស្មើនឹង៥៥,៤៧% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបខែតុលា ឆ្នាំ២០២១ ថយចុះចំនួន ៣១ ៤០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ១៣ ១០០តោន សរុបរយៈពេល១០ខែចំនួន ៥៦ ៩០០តោន ស្មើនឹង៤០,៦៤% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបខែតុលា ឆ្នាំ២០២១ កើនឡើងចំនួន ៩ ៩០០តោន។

៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ១១ ៨០០តោន សរុបរយៈពេល១០ខែចំនួន ១០១ ២០០តោន ស្មើនឹង៧៧,៨៥% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបខែតុលា ឆ្នាំ២០២១ កើនឡើងចំនួន ១ ៨០០តោន។

**៥.២ វារីវប្បកម្ម**

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ៤៦ ៤០០តោន សរុបរយៈពេល១០ខែចំនួន ២៩២ ៤០០តោន ស្មើនឹង ៨១,២២% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបខែតុលា ឆ្នាំ២០២១ កើនឡើងចំនួន ៦៥ ៥៦៦តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ២៥ ២០០ក្បាល សរុបរយៈពេល១០ខែចំនួន ១៣៣ ២០០ក្បាល ស្មើនឹង ៤៤,៤០% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបខែតុលា ឆ្នាំ២០២១ ថយចុះចំនួន ១១៩ ៦០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ៣០ ០០០ ០០០កូន សរុបរយៈពេល១០ខែចំនួន ១៨៨ ៥០០ ០០០កូន ស្មើនឹង៦២,៨៣% នៃផែនការចំនួន ៣០០ ០០០ ០០០កូន ប្រៀបធៀបខែតុលា ឆ្នាំ២០២១ ថយចុះចំនួនប្រមាណ ១៣២ ៩៦១ ២៨៨កូន។

**៥.៣ ការកែច្នៃផលនេសាទ**

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៣ ៧០០តោន សរុបរយៈពេល១០ខែចំនួន ៤០ ២០០តោន ស្មើនឹង៥០,២៥% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបខែតុលា ឆ្នាំ២០២១ ថយចុះចំនួន ២ ២៥០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ១ ១០០តោន សរុបរយៈពេល១០ខែចំនួន ៩ ៦៦០តោន ស្មើនឹង ៨០,៥០% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែតុលា ឆ្នាំ២០២១ កើនឡើងចំនួន ១០០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៣ ០០០ ០០០លីត្រ សរុបរយៈពេល១០ខែចំនួន ៤៣ ៧៥០ ០០០លីត្រ ស្មើនឹង ៨៧,៥០% នៃផែនការចំនួន ៥០ ០០០ ០០០លីត្រ ប្រៀបធៀបខែតុលា ឆ្នាំ២០២១ ថយចុះចំនួន ៤៥០ ០០០លីត្រ។

**៥.៤ ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផល**

- សំណុំរឿងបទល្មើសជលផលមានចំនួន ២៩៥ករណី ប្រៀបធៀបខែតុលា ឆ្នាំ២០២១ ថយចុះចំនួន ២៣១ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ២៧៥ករណី និងសមុទ្រចំនួន ២០ករណី។

**៥.៥ ការនាំចេញផលនេសាទ**

- ផលនេសាទស្រស់នាំចេញចំនួន ១២០តោន សរុបរយៈពេល១០ខែចំនួន ២ ៣៦២តោន ស្មើនឹង២៩,៥៣% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបខែតុលា ឆ្នាំ២០២១ ថយចុះចំនួន ៤៩៦តោន

- ផលនេសាទកែច្នៃនាំចេញសរុបរយៈពេល១០ខែចំនួន ៤១តោន ស្មើនឹង២,០៥% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបខែតុលា ឆ្នាំ២០២១ ថយចុះចំនួន ១០៩តោន។

**៥.៦ ការប្រមូលថវិកា**

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ៣១ ៣៦០ ០០០រៀល សរុបរយៈពេល១០ខែចំនួន ៥១០ ៣៦៥ ៨០៣រៀល ស្មើនឹង១៤២,០៨% នៃផែនការចំនួន ៣៥៩ ២០០ ០០០រៀល ប្រៀបធៀបខែតុលា ឆ្នាំ២០២១ ថយចុះចំនួន ២០ ៥២៦ ៦២៥រៀល។

## ៦- ផ្នែកអធិការដ្ឋាន

- ចុះពិនិត្យតាមដាន និងវាយតម្លៃលើការងារបង្ក្រាបបទល្មើសជលផលនៅខេត្តបាត់ដំបង

- ស្រាវជ្រាវព័ត៌មានតាមបណ្ដាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៥៧ករណី លើវិស័យព្រៃឈើ ១៣ករណី ជលផល២៤ករណី សុខភាពសត្វនិងផលិតកម្មសត្វ២ករណី កៅស៊ូ១ករណី អគ្គនាយកដ្ឋានកសិកម្ម ៨ករណី និងវិស័យផ្សេងៗ៩ករណី។

## ៧- ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៨៣០ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ៣៣៨ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៣២០ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១៧២ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៦៣៥ច្បាប់ ចេញប្រកាស សេចក្ដីសម្រេច និងសារាចរចំនួន ៨ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ៦ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែតុលា

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំ ដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- រៀបចំកិច្ចប្រជុំផ្ទៃក្នុង (អន្តរនាយកដ្ឋាន) ចំនួន ៧៨លើក មានសមាជិកចូលរួមចំនួន ២ ៨៧៦នាក់ និងកិច្ចប្រជុំអន្តរក្រសួងចំនួន ១២លើក មានសមាជិកចូលរួមចំនួន ១៨៣នាក់

- ទទួលភ្ញៀវអន្តរជាតិចំនួន ២២លើក មានសមាជិកចូលរួមចំនួន ១០៥នាក់

- សិក្ខាសាលាចំនួន ៩លើក មានសមាជិកចូលរួមចំនួន ១ ១១៤នាក់

- ពិធីចុះហត្ថលេខាចំនួន ៣លើក មានសមាជិកចូលរួមចំនួន ២៩៥នាក់

- សរុបការរៀបចំកិច្ចប្រជុំ ការទទួលភ្ញៀវ ពិធីចុះហត្ថលេខា និងសិក្ខាសាលាមានចំនួន ១១២លើក មានសមាជិកចូលរួមចំនួន ៣ ២៧៨នាក់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញ ផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារ កសិកម្ម)។

## ៨- ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៩២៤នាក់ (ស្រី១ ៤៧៥នាក់ ស្មើនឹង២៤,៨៩%)រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ៣ ០០៣នាក់ (ស្រី៨៧០នាក់ ស្មើនឹង២៨,៩៧%)
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩២១នាក់ (ស្រី៦០៥នាក់ ស្មើនឹង២០,៧១%)
- រៀបចំប្រកាសស្តីពីការផ្ទេរមន្ត្រីរាជការផ្ទៃក្នុងក្រសួងមានចំនួន ១០នាក់ (ស្រី១នាក់)
- រៀបចំប្រកាសស្តីពីការលុបឈ្មោះមន្ត្រីរាជការដែលបានលាឈប់ពីការងារចំនួន ២នាក់ (ស្រី២នាក់)
- រៀបចំប្រកាសស្តីពីការលុបឈ្មោះមន្ត្រីរាជការដែលបានទទួលមរណភាពចំនួន ២នាក់
- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន៣នាក់(ស្រី៣នាក់)
- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ២២៨នាក់ (ស្រី៥៧នាក់) ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ២០៧នាក់ (ស្រី៥២នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសចំនួន ១៦នាក់ (ស្រី៥នាក់)។

## ៩- ផ្នែកផែនការ និងស្ថិតិ

- ចូលរួមប្រជុំពិភាក្សាការធ្វើផែនការថវិកាឆ្នាំ២០២៣ របស់គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាគរបរិស្ថាន

- ចុះតាមដានការងារបង្កបង្កើនផលស្រូវវស្សា និងធ្វើការណែនាំសម្រាប់ធ្វើអង្កេតស្ទង់ទិន្នផលស្រូវវស្សាឆ្នាំ២០២២ ដោយសហការជាមួយមន្ត្រីស្ថិតិខេត្ត ស្រុកក្នុងខេត្តមណ្ឌលគិរី និងខេត្តត្បូងឃ្មុំ

- ចុះសិក្សាស្ថានភាពផលិតផល និងទីផ្សារកសិកម្មនៅខេត្តកំពង់ចាម កណ្តាល ប៉ៃលិន និងខេត្តសៀមរាប

- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងមួយសប្តាហ៍ រៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តទាំង២៥

- ចុះតាមដាន និងវាយតម្លៃការអនុវត្តសកម្មភាពថវិកាកម្មវិធីនៅខេត្តព្រៃវែង ខេត្តព្រះវិហារ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តឧត្តរមានជ័យ និងខេត្តព្រះសីហនុ។

## ១០- ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន ២ ៤៦៥លានរៀល

- បញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបចំនួន ៦ ២៨១លានរៀល

- រៀបចំសំណើសុំទូទាត់ថវិកាបុរេប្រទានឥណទានថវិកាជំពូក២១ (គម្រោងវិនិយោគផ្ទាល់) នៅដំណាក់-កាលទី១ និងដំណាក់កាលទី២ ចំនួន ៧ ៧១៣ ០០០ ០០០រៀល ជូននាយកដ្ឋានវិស្វកម្មកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្មសម្រាប់ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅតាមបណ្តាសហគមន៍កសិកម្មចំនួន ៧នៅក្នុងខេត្តកណ្តាល ត្បូងឃ្មុំ កំពង់ធំ និងខេត្តសៀមរាប

- ទទួលថ្លៃសម្បទានដីសេដ្ឋកិច្ចចំនួន ១២ក្រុមហ៊ុន

- ចុះពិនិត្យ និងបិទបញ្ជីគណនេយ្យការិយបរិច្ឆេទ២០២១ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី។

**១១- ផ្នែកសវនកម្មផ្ទៃក្នុង**

- រៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះក្នុងឆ្នាំ២០២១ ធ្វើសំណើសុំជម្រះសម្ភារខូចខាត ប្រើប្រាស់លែងកើត និងធ្វើការគ្រប់គ្រង បែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខារបច្ចេកទេសថែទាំ និងជួសជុល

- រៀចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស

- ចុះធ្វើសវនកម្មចំនួន ២៦សវនដ្ឋាន ស្មើនឹង៦៦,៦៦% នៃផែនការ៣៩សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន៩២អនុសាសន៍ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥៥,៨៥% នៃផែនការចំនួន៥៦%។

**១២- ផ្នែកសហប្រតិបត្តិការអន្តរជាតិ**

- សម្របសម្រួលរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-នូវែលសេឡង់ ដើម្បីត្រៀមរៀបចំកិច្ចពិគ្រោះយោបល់ក្រសួងការបរទេសកម្ពុជា-នូវែលសេឡង់លើកទី២

- សម្របសម្រួលរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យ វាយតម្លៃហានិភ័យផ្លែមៀនកម្ពុជាសម្រាប់ការនាំចេញទៅកាន់ប្រទេសចិន

- សម្របសម្រួលដើម្បីបន្តសុពលភាពអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម និងកសិ-ពាណិជ្ជកម្មរវាងក្រសួងកសិកម្មហ្វីលីពីន

- សម្របសម្រួលធ្វើលិខិតជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិសុំផ្តល់មតិយោបល់/ធាតុចូលលើសេចក្តីព្រាងឯកសារផែនការសកម្មភាព៥ឆ្នាំ នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងឆ្នាំ២០២៣-២០២៧

- សម្របសម្រួលលិខិតករណីសំណើផ្តល់ធាតុចូលលើវិស័យអាទិភាពដែលស្នើឡើងដោយកម្ពុជា សម្រាប់ផែនការការងារនៃកិច្ចសហប្រតិបត្តិការអាស៊ានបូកបីឆ្នាំ២០២៣-២០២៧

- សម្របសម្រួលការចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើដំណាំឧស្សាហកម្មចេករវាងកម្ពុជា-ចិន

- សម្របសម្រួលការចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការកម្មវិធីកសិករតាមរដូវកាលរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងខេត្ត Yanggu របស់ប្រទេសកូរ៉េ

- សម្របសម្រួលសុំគោលការណ៍អនុញ្ញាតចុះហត្ថលេខាអនុស្សរណៈនៃការយោគយល់គ្នារវាងវិទ្យាស្ថាន និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ និងវិទ្យាស្ថានព្រៃឈើអាស៊ាននៃប្រទេសកូរ៉េ។

**១៣- ផ្នែកនីតិកម្មកសិកម្ម**

**១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម**

- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចេញថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មចំនួន ២ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្មចំនួន ១ក្រុមហ៊ុន។

**១៣.២ ការងារមន្ទីរពិសោធន៍**

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៧ក្រុមហ៊ុន សរុបចំនួន ៧២សំណាក។

**១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត**

- សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈនៅខេត្តស្ទឹងត្រែង។

**១៣.៤ ការងារអនុវត្តច្បាប់**

- ចុះត្រួតពិនិត្យក្រុមហ៊ុនប្រកាសប្រតិវេទន៍នាំចូលថ្នាំកសិកម្ម ជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយដល់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១១ក្រុមហ៊ុន

- ចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មខេត្តមណ្ឌលគិរី និងខេត្តរតនគិរី ដោយត្រួតពិនិត្យលើដេប៉ូ៣ដេប៉ូ ធ្វើការអប់រំណែនាំដោយពុំមានពិន័យអន្តរការណ៍ទេ។

## ១៤- ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- តាមដាន និងផ្សព្វផ្សាយលើគេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត លើគេហទំព័រ សរុបចំនួនផុស ៣៥៥ព័ត៌មាន

- បន្តជំរុញការផ្សព្វផ្សាយឯកសារបច្ចេកទេសកសិកម្ម សេចក្តីជូនដំណឹង សារាចរណែនាំ សេចក្តីសម្រេច ប្រកាស និងលិខិតបទដ្ឋានគតិយុត្ត ឲ្យបានទូលំទូលាយលើបណ្តាញផ្សព្វផ្សាយសង្គម (ហ្វេសប៊ុក) និងគេហទំព័រ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសរុបចំនួន១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រាជធានី-ខេត្ត

- បន្តចុះប្រមូលទិន្នន័យដំណាំសក្តានុពលក្នុងស្រុកប្រាសាទបល្ល័ង្ក នៅខេត្តកំពង់ធំ ដើម្បីរៀបចំជាផែនទី ដំណាំកសិកម្មដែលស្ថិតនៅក្នុងភូមិសាស្ត្រឃុំសាមគ្គី

- តាមដាន និងថែទាំម៉ាស៊ីន Firewall ដើម្បីទប់ស្កាត់ការយាយីពីអ្នកខាងក្រៅ (Hacker)

- ទទួលសៀវភៅឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តីដែលទទួលបានពីរដ្ឋបាល និងផ្នែកផ្សេងៗសរុប ចំនួន៣ក្បាល/ច្បាប់។

## ១៥- ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ចុះថត និងផលិត Video បទយកការណ៍ចំនួន ៨ប្រធានបទ

- ធ្វើការចាក់ផ្សាយឡើងវិញវេទិកាស្វែងយល់អំពីកសិកម្មចំនួន ៨ប្រធានបទ

- ធ្វើការចាក់ផ្សាយឡើងវិញនាទីចុះស្រែជាមួយកសិករចំនួន ៨ប្រធានបទ

- ធ្វើការចាក់ផ្សាយអត្ថបទបច្ចេកទេសកសិកម្មជាសំឡេងនៅស្ថានីយវិទ្យុជាតិ FM105.70.75MHZ ចំនួន ៥៤ប្រធានបទ

- គេហទំព័រ www.khmeragri.info/www.deaff.maff.gov.kh មានអ្នកទាញយកឯកសារផ្សេងៗចំនួន ២៥១ ២៨៤ដង អ្នកចូលមើលចំនួន ៧៩៣ ៥២៦នាក់ និងដាក់បញ្ចូលឯកសារសរុបចំនួន ៨១២ឯកសារ

- ជួយដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជនចំនួន ៥៩១សំណួរ-ចម្លើយលើប្រធានបទបច្ចេកទេសដំណាំកាហ្វេ ផ្សិតចំបើង ដំឡូងមី ដំឡូងជ្វា ពោត ម្ទេស ក្រូចឆ្មា ក្រូចថ្លុង សណ្តែក និងស្ពៃ ផ្តល់ព័ត៌មានជូនកសិករនូវសៀវភៅឯកសារចិញ្ចឹមត្រីប្រា ត្រីឆ្តោ កង្កែប កន្ធាយ ទា មាន់ និងជំងឺជុំពកលើសត្វគោ។

## ១៦- ផ្នែកកសិ-ឧស្សាហកម្ម

- អនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មចំនួន ២៦១កិច្ចសន្យា រួមមាន ខេត្តពោធិ៍សាត់៤២កិច្ចសន្យា ស្ទឹងត្រែង ៧កិច្ចសន្យា តាកែវ៥កិច្ចសន្យា មណ្ឌលគិរី១កិច្ចសន្យា កំពង់ស្ពឺ៣៦កិច្ចសន្យា កែប៤កិច្ចសន្យា កណ្តាល១៥កិច្ចសន្យា ក្រចេះ១៤កិច្ចសន្យា ព្រះវិហារ៣៧កិច្ចសន្យា ត្បូងឃ្មុំ២០កិច្ចសន្យា សៀមរាប១១កិច្ចសន្យា កំពង់ចាម៤កិច្ចសន្យា ស្វាយរៀង៣កិច្ចសន្យា បន្ទាយមានជ័យ១៥កិច្ចសន្យា កំពង់ធំ៨កិច្ចសន្យា ប៉ៃលិន១២កិច្ចសន្យា បាត់ដំបង១កិច្ចសន្យា និងកំពង់ឆ្នាំង១៦កិច្ចសន្យា

- រៀបចំកិច្ចប្រជុំពិនិត្យឯកសារស្តីពីការវិភាគបែបគុណភាពនៃប្រព័ន្ធត្រួតពិនិត្យម្ហូបអាហារនៅកម្ពុជា

- ចូលរួមទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរបទពិសោធន៍ថ្នាក់តំបន់អំពីការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា រវាងប្រទេសកម្ពុជា ប្រទេសឡាវ និងប្រទេសវៀតណាម នៅទីក្រុងហាណូយ ប្រទេសវៀតណាម

- ចុះអង្កេតស្រាវជ្រាវករណីសង្ស័យពុលសារធាតុគីមី (ថ្នាំកសិកម្ម) ក្នុងកសិដ្ឋានចម្ការចេក បេងកេត នៅក្នុងភូមិ៣៥ ឃុំព្រែកកក់ ស្រុកស្ទឹងត្រែង ខេត្តកំពង់ចាម។

## ១៧- ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះពិនិត្យការអនុវត្តការផលិតស្រូវចំណីតាមកិច្ចសន្យារបស់កសិករគោលដៅនៅខេត្តបន្ទាយមានជ័យ និង ខេត្តបាត់ដំបង

- ចុះរៀបចំទិវាចម្ការពិសោធន៍បង្ហាញស្តីពីការប្រើប្រាស់ជីលើដំណាំសណ្តែកដីនៅខេត្តកំពង់ស្ពឺ

- ចុះសិក្សាវាយតម្លៃដី និងវាស់វែងទិន្នន័យពិសោធន៍នៅខេត្តកំពង់ធំ និងខេត្តព្រះវិហារ

- ចុះត្រួតពិនិត្យ និងប្រមូលទិន្នន័យពិសោធន៍នៅខេត្តតាកែវ កំពត និងខេត្តព្រៃវែង
- ចុះត្រួតពិនិត្យការងារពិសោធន៍នៅខេត្តព្រះវិហារ និងខេត្តត្បូងឃ្មុំ
- ចុះពិនិត្យការងារគ្រប់គ្រងទូទៅ និងផលិតកម្មគ្រាប់ពូជដំណាំស្រូវនៅខេត្តព្រះវិហារ
- ចុះពិភាក្សាការងារពិសោធន៍ និងបើកវគ្គបណ្តុះបណ្តាលដែលមានអ្នកចូលរួមសរុបចំនួន ១០០នាក់ នៅខេត្តព្រៃវែង និងខេត្តតាកែវ
- ចុះប្រមូលផលផលិតកម្មពូជពោតនៅខេត្តកំពង់ចាម
- ចុះប្រមូលទិន្នន័យ និងរៀបចំទីកន្លែងសម្រាប់ប្រតិភូពិនិត្យស្រែបង្ហាញនៅខេត្តតាកែវ និងខេត្តព្រៃវែង
- ចុះប្រមូលទិន្នន័យអំពីការប្រើប្រាស់ជីលើដំណាំរបស់កសិករនៅខេត្តត្បូងឃ្មុំ។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២២សរុបចំនួន ៣ ១៤៤នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម
- ទទួលគណប្រតិភូធនាគារពិភពលោក ដឹកនាំដោយ Mr. Cristian Aedo នាយកប្រតិបត្តិផ្នែកអប់រំប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក និងអគ្គនាយកដ្ឋានឧត្តមសិក្សា ចុះត្រួតពិនិត្យការអនុវត្តគម្រោងកែលម្អការអប់រំឧត្តមសិក្សា
- រៀបចំកម្មវិធីផ្សព្វផ្សាយស្តីពីការអប់រំ បង្ការ ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន ការជួញដូរគ្រឿងញៀន
- ចុះអនុស្សរណៈយោគយល់គ្នារវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងក្រុមហ៊ុនអង្គរហ្វ្រីដ ដើម្បីផ្លាស់ប្តូរចំណេះ ជំនាញ និងបទពិសោធន៍
- ជួបប្រជុំពិភាក្សាស្តីពីការគូសផែនទីគុណភាពទឹកនៅប្រព័ន្ធបឹងទន្លេសាបដែលបានរៀបចំឡើងដោយគម្រោងអច្ឆរិយភាពនៃទន្លេមេគង្គ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជំងឺឆ្លងពីសត្វមកមនុស្ស និង Participatory Epidemiology នៅ Wildlife Alliance ។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២២ សរុបចំនួន ១ ២៦២នាក់ (ស្រី៤៩៦នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស
- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូ ដើម្បីជាប្រយោជន៍សម្រាប់ការសិក្សាស្រាវជ្រាវរបស់និស្សិត និងមន្ត្រីដោយការសិក្សាស្រាវជ្រាវផ្តោតលើៈ ត្រី បង្កង បង្គា មាន់ ទា ពពែ ក្របី គោទឹកដោះ បន្លែ ផ្កា ឫស្សី ស្រូវ ចេក ស្វាយចន្ទី កាកាវ វ៉ានីឡា ស្មៅ អាហារ ថ្នាំសត្វល្អិត និងជី
- សហប្រតិបត្តិការសំខាន់ៗរួមមានការបណ្តុះជាលិការុក្ខជាតិ អាក្វាពោនិក (ប្រព័ន្ធវារីវប្បកម្ម) ការកែច្នៃស្វាយចន្ទី ការផលិតម្សៅឫស្សី ការចិញ្ចឹមគោទឹកដោះ ការពិសោធដំណាំជប៉ុន និងការសរសេរសៀវភៅសម្រាប់ការបណ្តុះបណ្តាលរបស់វិទ្យាស្ថាន។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២២ សរុបចំនួន ៥៩៤នាក់ (ស្រី២០៩នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- ពិសោធន៍លើការចម្រាញ់ប្រេងរុក្ខជាតិដូចជា ស្លឹកគ្រៃ ស្លឹកក្រូចសើច និងម្រេច
- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់
- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា
- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម

- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

**១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

- តាមដាន ស្រង់ វិភាគទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយទាំងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូសរុបចំនួន ៦២ពិសោធន៍

- ថែទាំកូនកៅស៊ូ Tissue Culture Plant ចំនួន ២៥០០កូន ដែលទទួលមកពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន (RRI-CATAS)

- ចុះយកសំណាកទឹកជ័រចម្ការពិសោធន៍ក្លូនទ្រង់ទ្រាយធំសរុបចំនួន ១៨៤សំណាក

- យកសំណាក និងវិភាគសរីរទឹកជ័រចម្ការកៅស៊ូក្នុងស្ថានីយពិសោធន៍ចំនួន ៦៤០សំណាក

- ដាក់ជីបំប៉នលើកទី២លើកូនកៅស៊ូមិនទាន់ផ្តល់ផលលើផ្ទៃដី៣១,២៥ហ.ត និងចម្ការពិសោធន៍ជីលើកៅស៊ូផ្តល់ផលលើផ្ទៃដី១៥,២០ហ.ត

- ចូលរួមធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍ក្នុងក្របខណ្ឌសមាគមន៍កៅស៊ូអន្តរជាតិជាមួយ International Rubber Association (IRA ) លើកទី១២៧

- ចុះពិនិត្យ និងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូរបស់ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ ខ្ញ., អិលធីឌី។

## III- សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបានចំនួន ២ ៧៦៤ ០៤០ហ.ត ស្មើនឹង១០៥,៥២% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត និងការប្រមូលផលស្រូវស្រាលសម្រេចចំនួន ៥៦៧ ៩៩៩ហ.ត ទទួលបរិមាណផលសរុបចំនួន ២ ២៥០ ១៣៨តោន និងទទួលបានទិន្នផលគិតជាមធ្យម ៣,៩៦២តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសមាសភាពចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការដាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈឺក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

**១- ផ្នែកដាំដុះ**

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្ម

- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩

- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្ត បច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រ ដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និង បន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមាន គ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹង សហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយ បច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

## ២- ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដាន លើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើ អនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះ ជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅ ជាប់ព្រំដែន

- បន្តពង្រឹង និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វដល់កសិករ

- ត្រៀមលក្ខណៈចុះអនុវត្តវិធានការបសុព្យាបាលកន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ជំងឺដុំពកស្បែកគោ ក្របី (LSD) និងជំងឺឆ្លងសត្វផ្សេងៗ

- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាម ខេត្តគោលដៅ

- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

## ៣- ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃ ឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បី បង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផល ប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូន ដំណឹង លេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាប ដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាង

មុឹងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីរំលោភយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

## ៤- ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការសហគមន៍នេសាទគ្មានបទល្មើសជលផល។

## ៥- ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។/.

ថ្ងៃសុក្រ ១១កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**